# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016
## (សេដ្ឋកិច្ច ក្រុមទី៩៖ ធុរកិច្ចបរិស្ថាន)

លេខ: 10 PR-17/EoJ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧

តាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន១៩រូប នឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី១៥ ដល់ថ្ងៃទី២៣ ខែឧសភា ជាមួយក្រុមយុវជនមកពីបណ្តាប្រទេសអាស៊ាន និងទីម័រខាងកើត ក្រោមកម្មវិធីបណ្តាញផ្លាស់ ប្តូរសិស្សនិស្សិត និងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែល ហៅកាត់ថា JENESYS 2016។

ក្រោយការទស្សនានៅទីក្រុងតូក្យូ ក្រុមយុវជននឹងទៅទស្សនាខេត្តហ្វូគូអុកា ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរទំនាក់ទំនងជាមួយស្ថាប័ន និងក្រុមហ៊ុនផ្សេងៗ ពាក់ព័ន្ធនឹងធុរកិច្ចបរិស្ថាន។ ក្រុមយុវជនក៏នឹងមានឱកាសទៅទស្សនាតំបន់ប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួនផងដែរ។ មានជូនភ្ជាប់តារាងកម្មវិធីលម្អិត។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងការកសាង nb ទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់ហើយ តាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែស៊ីជំរៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជា បន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Fax: 023 216 162*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*